**BMI0059**

# សម្ភាសន៍ជាមួយឈ្មោះ ថោង ដែន ភេទប្រុស អាយុ៥៩ឆ្នាំ

# មុខងារជំនាន់ខ្មែរក្រហមៈ “កាន់ខាងភាស់ភា”

# មុខងារបច្ចុប្បន្នៈ“កសិករ”

# ស្រុកកំណើតនៅភូមិកំព្រាល ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ

# រស់នៅវាលហាត់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

# ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០

# សម្ភាសន៍ដោយៈ សុខ វណ្ណៈ

# ០០:៥៥:២៥

# ២២ទំព័រ

វណ្ណៈ: ចឹងខ្ញុំមុនហ្នឹងចាប់ផ្ដើមសម្ភាសន៍ខ្ញុំសូមណែនាំខ្លួនថាខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំឈ្មោះ សុខ វណ្ណៈ ។

ដែន : បាទ ។

វណ្ណៈ: ហើយខ្ញុំមកដល់ស្រុកម៉ាឡៃនេះដើម្បីស្រាវជ្រាវចងក្រងជាសៀវភៅប្រវត្តិម៉ាឡៃ ដើម្បីឲ្យ ឲ្យក្មេងជំនាន់ក្រោយបានដឹងបានព្ទ ។

ដែន : បាទ ។

វណ្ណៈ: ហើយបទសម្ភាសន៍ខ្ញុំជាមួយពូហ្នឹង ខ្ញុំសូមយកទៅសរសេរជាសៀវភៅទាក់ទងនិងស្រុកម៉ាឡៃ តើពូអនុញ្ញាតទេ?

ដែន : បានមិនអីទេ ឲ្យតែខាងលើគេអនុញ្ញាតមកហើយបានមិនអីទេ ។

វណ្ណៈ: ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូដែរ?

ដែន : ខ្ញុំឈ្មោះ ថោង ដែន ។

វណ្ណៈ: ពូអាយុប៉ុន្មានហើយ?

ដែន : អាយុ៥៩ ។

វណ្ណៈ: ចឹងប្រពន្ធពូឈ្មោះអីដែរ?

ដែន : ឈ្មោះជា លំ ។

វណ្ណៈ: ចឹងសព្វថ្ងៃពូមានកូនចៅប៉ុន្មាននាក់?

ដែន : ៦នាក់ ។

វណ្ណៈ  ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ដែន  :  ស្រី៣ប្រុស៣ ។

វណ្ណៈ  ឪពុកពូឈ្មោះអី?

ដែន  :  ឈ្មោះថោង  ហ៊ឹម ។

វណ្ណៈ  ម្ដាយ?

ដែន  :  ម្ដាយឈ្មោះចាប  អេង ។

វណ្ណៈ  ចឹងសព្វថ្ងៃគាត់នៅរស់ទេ?

ដែន  :  ម្ដាយស្លាប់ហើយនៅឪពុក ។

វណ្ណៈ  ចឹងបងប្អូនបង្កើតពូមានប៉ុន្មាននាក់?

ដែន  :  បងប្អូនបង្កើតមាន៧នាក់ ។

វណ្ណៈ  នៅរស់ទាំងអស់?

ដែន  :  នៅរស់៥នាក់ស្លាប់ពីរ ។

វណ្ណៈ  ស្លាប់នៅជំនាន់ណា?

ដែន  :  មួយស្លាប់ជំនាន់យើងរដ្ឋកម្ពុជាហ្នឹង ។

វណ្ណៈ  ក្រោយ៧៩?

ដែនៈ  បាទ ។

វណ្ណៈ  ហើយមួយទៀត?

ដែនៈ  មួយទៀតស្លាប់មុន៧៩ ។

វណ្ណៈ  ចឹងរាល់ថ្ងៃនេះពូប្រកបមុខរបរអីដែរ?

ដែន  :  សព្វថ្ងៃខ្ញុំធ្វើចំការ ។

វណ្ណៈ  ចឹងភូមិកំណើតនៅទីណា?

ដែន  :  ភូមិកំណើតនៅភូមិកំព្រាល ។

វណ្ណៈ  ឃុំ?

ដែន  :  ឃុំប្រឡាយ ។

វណ្ណៈ  ស្រុក?

ដែន  :  ស្រុកស្ទោង ។

វណ្ណៈ  ខេត្តកំពង់ធំ?

ដែនៈ  បាទ ។

វណ្ណៈ ចឹងឥឡូវនៅភូមិណា?

ដែន ៖ នៅភូមិវាលហាត់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ កាលមុនខេត្តបាត់ដំបង?

ដែនៈ បាទ! នៅបាត់ដំបង ។

វណ្ណៈ ចឹងខ្ញុំចង់ឲ្យពូរៀបរាប់ថា រឿងរ៉ាវដែលធ្លាប់ឆ្លងកាត់តាំងពីតូចមកហើយពូរៀនបានត្រឹមណាពូរៀននៅសាលាណាសូមពូជួយរៀបរាប់ផង?

ដែន ៖ កាលពីតូចខ្ញុំចូលរៀននៅឆ្នាំ១៩៦៣ កាលហ្នឹងរៀនបានថ្នាក់ទី៧ មានដល់ឆ្នាំ១៩៦៩ខ្ញុំឈប់ធ្វើស្រែបានមួយឆ្នាំបានខ្ញុំឈប់ចូលបដិវត្តន៍ ។

វណ្ណៈ ចឹងចូលបដិវត្តន៍នៅឆ្នាំ១៩៧០?

ដែនៈ បាទ ។

វណ្ណៈ ហើយយ៉ាងម៉េចទៀត?

ដែន ៖ ខ្ញុំចូលបដិវត្តន៍ខ្ញុំបានចូលបំរើកងទ័ពនៅភូមិភាគ៣០៤ ។

វណ្ណៈ ចឹងនៅ៣០៤ហ្នឹងពីណាជាអ្នកគ្រប់គ្រង?

ដែន ៖ កាលនៅ៣០៤ហ្នឹងកុយ ធួន ជាអ្នកគ្រប់គ្រងនៅភូមិភាគឧត្តរ ។

វណ្ណៈ យ៉ាងម៉េចទៀត?

ដែន ៖ បានមកដល់ពេលរំដោះភ្នំពេញ នៅថ្ងៃ១៧មេសា ខ្ញុំចូលមកភ្នំពេញ ។

វណ្ណៈ ចឹងចូលភ្នំពេញដំបូង?

ដែន ៖ បាទ! បានចូលមកដល់ដំបូង ។

វណ្ណៈ ចឹងពេលដែលចូលទៅនៅម៉ោងប៉ុន្មាន?

ដែន ៖ ខ្ញុំចូលនៅពេលដែលគេរំដោះហើយប្រហែលជា១០ថ្ងៃបានខ្ញុំទៅ ។

វណ្ណៈ ចឹងបានដល់ភ្នំពេញ?

ដែនៈ បាទ ។

វណ្ណៈ ចឹងថ្ងៃ១៧ហ្នឹងមិនបានចូលទេ?

ដែន ៖ បាទ! មិនបានចូលទេ ។

វណ្ណៈ ចឹងបន្ទាប់មកទៀតយ៉ាងម៉េចពូ?

ដែន ៖ ដល់ពេលបានចូលដល់ភ្នំពេញខ្ញុំបានចូលធ្វើការនៅឃ្លាំងរដ្ឋ ។

វណ្ណៈ នៅឃ្លាំងរដ្ឋហ្នឹងធ្វើអីគេដែរ?

ដែន ៖ កាលហ្នឹងមើលឃ្លាំងសម្ភារជ័យភ័ណ្ឌនិងលីសែង ជាកម្មករលីសែងផងមើលសម្ភារជ័យភ័ណ្ឌផង ។

វណ្ណៈ៖ មើលសម្ភារជ័យភ័ណ្ឌហ្នឹងមើលជារបៀបយ៉ាងម៉េច?

ដែន ៖ កាលហ្នឹងគេប្រមូលដាក់ក្នុងឃ្លាំងតាមផ្ទះក្នុងភ្នំពេញទាំងអស់ ។

វណ្ណៈ៖ បាទ ។

ដែន៖ យើងប្រមូលទុកដាក់តាមសហករណ៍ណាតាមកម្មករពោងចក្រណាគេត្រូវការរបស់របរអី១ យើងប្រមូលដាក់តាមផ្ទះហើយយើងរៀបចំតាមផ្នែក១វា ។

វណ្ណៈ៖ បាទ ។

ដែន៖ រៀបចំសម្ភារដាក់តាមផ្នែកវាចឹងទៅដូចជាតាមសហករណ៍ឬតាមអង្គភាពត្រូវការសម្ភារអីគេមករកទៅ យើងមានយើងដោះស្រាយជូនគេទៅ ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូធ្វើនៅភ្នំពេញរហូតឬនៅខាងណាទៀត?

ដែន ៖ ខ្ញុំនៅហ្នឹងរហូតរយៈពេលបីឆ្នាំហ្នឹងរហូតដល់ថ្ងៃទី៧មករាហ្នឹងបានខ្ញុំរត់ចេញពីភ្នំពេញ ។

វណ្ណៈ៖ ចឹងពី៧៥ដល់៧៩?

ដែន៖ បាទ១ ។

វណ្ណៈ៖ នៅភ្នំពេញរហូត?

ដែន៖ បាទ ។

វណ្ណៈ៖ ចឹងនៅភ្នំពេញរយៈពេលបីឆ្នាំជាងហ្នឹងពូនៅខាងឃ្លាំងរហូតឬមួយពូដោះដូរនៅខាងណាផ្សេងទៀត?

ដែន ៖ អត់ទេខ្ញុំនៅខាងឃ្លាំងរហូតកំលាំងមួយវរៈសេនាតូចហ្នឹងចាំមើលឃ្លាំងដាក់ម្នាក់ពីរនាក់តាមច្រកតាមផ្សារ ។

វណ្ណៈ៖ បាទ ។

ដែន៖ មើលទៅនៅសល់កំលាំងប៉ុន្មានមកជួយលីសែងគេទៅនៅជ្រោយចង្វានិងគីឡូលេខ៦ ។

វណ្ណៈ៖ ចឹងមានមកលីសែងដែរ?

ដែន៖ បាទ ។

វណ្ណៈ៖ ចឹងពីណាគេជាអ្នករគប់គ្រងនៅឃ្លាំងហ្នឹង?

ដែន ៖ អ្នកដែលគ្រប់គ្រងនៅឃ្លាំងមួយក្រសួងហ្នឹងឈ្មោះវឿង វឿងហ្នឹងឈ្មោះគាត់មានពីរមួយវឿងហៅរិទ្ធ ។

វណ្ណៈ៖ បាទ ។

ដែនៈ តែជាទូទៅគេហៅរឿង តែរិទ្ធហ្នឹងមានពីរនាក់ តែមួយឈ្មោះរិទ្ធដែរ តែគាត់កាន់ពាណិជ្ជកម្មក្រៅប្រទេស ហ្នឹងអ៊ីរិទ្ធដែលចាស់នោះ ទេតែរិទ្ធកាន់ខាងឃ្លាំងនៅក្នុងជាង ។

វណ្ណៈ៖ ចឹងរិទ្ធហ្នឹងគ្រប់គ្រងតែមួយឃ្លាំងឬគ្រប់គ្រងមួយប្រទេស?

ដែន ៖ អត់ទេ រិទ្ធហៅរឿងហ្នឹងគ្រប់តែឃ្លាំងទេនិងកម្មករលើសែងទាំងអស់ ។

វណ្ណៈ៖ គ្រប់គ្រងឃ្លាំងនិងកម្មករទាំងអស់?

ដែនៈ បាទ ។

វណ្ណៈ៖ ចឹងតារិទ្ធមួយទៀតគាតមានទូនាទីអីតា រិទ្ធ?

ដែន ៖ តារិទ្ធសក់សហ្នឹង ។

វណ្ណៈ៖ បាទ ។

ដែនៈ គាត់ទទួលនាទីខាងពាណិជ្ជកម្មក្រៅប្រទេសនោះវិញ ។

វណ្ណៈ៖ តែគ្រប់គ្រងទាំងអស់ទាំងកម្មករឃ្លាំងអីលើគាត់ទាំងអស់?

ដែនៈ អត់ទេ ។

វណ្ណៈ៖ ចឹងតារិទ្ធខាងផ្នែក?

ដែនៈ ខាងផ្នែកក្រៅប្រទេសទៅខាងកំពង់សោមហ្នឹងគឺគាត់ គាត់មិនដឹងជាគ្រប់គ្រងយ៉ាងម៉េចទេ តែមើលក្នុងនេះគាត់ គាត់កាន់ពាណិជ្ជកម្មក្រៅប្រទេស ។

វណ្ណៈ៖ ចឹងពាណិកម្មកាលជំនាន់ហ្នឹងមានអីខ្លះទេតាមពូដឹង?

ដែនៈ ពាណិជ្ជកម្មក្នុងប្រទេស ។

វណ្ណៈ៖ បាទ ។

ដែន ៖ អាហ្នឹងសម្ភារដែលយកពីក្រៅមកត្រូវយកដាក់ឃ្លាំងដែរ ។

វណ្ណៈ៖ បាទ ។

ដែនៈ ខ្ញុំដឹងតែក្នុងក្របខណ្ឌឃ្លាំងទេ ។

វណ្ណៈ៖ ចឹងពូនៅឃ្លាំងរហូត?

ដែនៈ បាទ! ដែកសម្ភារក្រណាត់អីច្រើនដែលណា ។

វណ្ណៈ៖ ចឹងមានដែកដែរ?

ដែនៈ មានដែកក្រណាត់អី ។

វណ្ណៈ៖ ចឹងក្រណាត់ខាងរោងចក្រយើងធ្វើបានដែលហ្នឹងយកទៅណា?

ដែន ៖ តាមរោងចក្រធ្វើបានទេ យកមកដាក់ក្នុងឃ្លាំងដែរឬក៏យ៉ាងម៉េចទេ តែមកក្រណាត់ក៏មានមកដែរ អាហ្នឹងមានដុំកីមូលៗ ។

វណ្ណៈ  របស់យើងមានកប្បាសមានគមានអីដែរ?

ដែនៈ   បាទ ។

វណ្ណៈ  កំលាំងកម្មករនារីនៅភ្នំពេញធ្វើចឹងនៅពេលចប់ឆ្នាំ៧៥ ហើយលែងមានកំាភ្លើងទៀតហើយចឹង ទាហានក្លាយជាកម្មករមែនទេពូ?

ដែន  :  បាទ ។

វណ្ណៈ  ចឹងសម្ភារដែលធ្វើបានហ្នឹងពូមិនដឹងជាគេយកទៅណាទេ?

ដែន  :  បាទ!  គ្រណាត់ដែលមកពីក្រៅមកត្រូវចូលក្នុងឃ្លាំង  ឃ្លាំងនេះដល់ពេលថាសហករណ៍នៅណា នៅស្រុណាខេត្តណាមកស្នើរហ្នឹង  ពួកខ្ញុំជាអ្នកលីចុះមកដាក់កប៉ាល់ឬគាមឡានចេញពីឃ្លាំងទៅ ដូចជារបស់របរដូចជាស្រូវដូចជារបស់អីផ្សេងៗហ្នឹងចេញទៅក្រៅត្រូវចូលមកឃ្លាំងដែរ  បាន កិនជាអង្ករចេញទៅខាងក្រៅទៀត ។

វណ្ណៈ  ចឹងអ្នកកាន់ឃ្លាំងហ្នឹងមានគ្នាច្រើនទេ?

ដែន  :  មានច្រើនណាស់  ទាំងកម្មករទាំងអ្នកមើលឃ្លាំងនិងអ្នកលីសែងមានវរៈ៧១វរៈ៧២វរៈ៧៣វរៈ ៧៤វរៈ៧៥វរៈ៧៦  មាន៧វរៈសេនាតូច  ដោយឡែកមុខព្រួយខ្ញុំកំលាំងត្រូវមួយវរៈដែរ  មួយ កងហ្នឹងគេដែរ ។

វណ្ណៈ  ចឹងមានកងវរៈទី១ដល់ទី៧?

ដែនៈ   បាទ!ដល់ទី៧ ។

វណ្ណៈ  ចឹងកាលហ្នឹងប្រធានកងពលដូចជាកុយ  ធួនទៅធ្វើអីវិញពូមានបានដឹងទេ?

ដែន  :  កុយ  ធួន  ប្រធានភូមិភាគឧត្តរដល់ពេលគាត់មកដល់ភ្នំពេញ  កាលអីវិទ្ធមិនទាន់ឡើង  កុយ  ធួន ទទួលខុសត្រូវខាងពាណិជ្ជកម្មក្នុងស្រុកនិងក្រៅប្រទេសទាំងអស់ ។

វណ្ណៈ  ចឹងនៅពេលដែលអង្គការចាប់ខ្លួនកុយ  ធួនពូមានបានដឹងទេ?

ដែន  :  កាលហ្នឹងបានដឹង  គេចាប់ហើយដឹង ។

វណ្ណៈ  ចឹងកូនចៅដែលធ្លាប់ធ្វើការជាមួយគាត់មានអារម្មណ៍យ៉ាងម៉េចដែរ  ដូចជាពូមានអារម្មណ៍ភ័យ ខ្លាចគេចាប់ដែលឬយ៉ាងម៉េច?

ដែន  :  ទេខ្ញុំកាលហ្នឹងខ្ញុំដូចជាមិនមានអារម្មណ៍ភ័យខ្លាចទេ  ខ្ញុំតាំងពីចូលធ្វើការមកមិនមានបានចូលរួម ទទួលការអប់រំពីរឿងបំផ្លិចបំផ្លាញឬមួយបានចូលរួមក្បត់អី ។

វណ្ណៈ  បាទ ។

ដែន  :  អត់មានដែលបានទទួលការណែនាំដូចគេឯងចឹង  ខ្ញុំដូចជាអត់ភ័យធម្មតា ។

វណ្ណៈ៖ ចឹងកាលជំនាន់ហ្នឹងពូមានដែលឃើញគណៈប្រតិភូធំៗទៅកន្លែងឃ្លាំងហ្នឹងដែលទេឬមួយពូមានបានមកប្រជុំជាមួយគា ប៉ុល ពតទេឬក៏យ៉ាងម៉េចដែលជំនាន់ហ្នឹង?

ដែន ៖ ធ្លាប់ ឃើញគា នួន ជា ខៀវ សំផន។

វណ្ណៈ៖ ចឹងនៅពេលដែលគាត់ប្រជុំហ្នឹង គាត់មាននិយាយរឿងអីខ្លះទៅ?

ដែន ៖ ប្រជុំភាគច្រើននិយាយពីការងារថា សន្និបាតបំណាច់ឆ្នាំហ្នឹងឲ្យសម្រេចបាននូវផែនការឆ្នាំណាអីឆ្នាំណាហ្នឹងនិយាយពីការងារបូកសរុបការងារ និយាយថាឲ្យពូរឿងឲ្យបំផ្លិចបំផ្លាញចេះចុះមិនដែលពូទេ។

វណ្ណៈ៖ បាទ។

ដែនៈ បាទ!មិនដែលពូមាន។

វណ្ណៈ៖ ចឹងនៅក្នុងរយៈពេលបីឆ្នាំហ្នឹងពូមានបានចូលប្រជុំច្រើនដងទេ?

ដែន ៖ ក្នុងមួយឆ្នាំសន្និបាតម្តងៗរាល់ឆ្នាំ។

វណ្ណៈ៖ ចឹងមានប៉ុល ពតខៀវ សំផនដែរ?

ដែនៈ មានខៀវ សំផន។

វណ្ណៈ៖ ចឹងកាលហ្នឹងពូមានបានដឹងថា អង្គការចាប់មេដឹកនាំធំៗខ្លះដូចថាយុវជនមួយចំនួនយកទៅណាទៅណីមានទេជំនាន់ហ្នឹង?

ដែន ៖ នៅកន្លែងខ្ញុំពួកខ្ញុំមាន មានមេៗលើៗខ្ញុំមានគេចាប់ តែមិនបានដឹងថាគេយកទៅណាទេ។

វណ្ណៈ៖ ចឹងនៅឆ្នាំ១៩៧៧-៧៨ហ្នឹងពូមានបានដឹងថាគេសម្លាប់មនុស្សអីទេ?

ដែន ៖ ដឹងដែរ តែមិននឹកស្មានថាច្រើនម្លេះ។

វណ្ណៈ៖ ចឹងដឹងដែរ?

ដែនៈ បាទ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូមានបានដឹងពត៌មានខាងក្រោយថាស្រុកភូមិអីហូបចុកលំបាកដឹងទេឬមិនបានដឹងទេកាលហ្នឹង?

ដែន ៖ទេខ្ញុំបានដឹង កាលឆ្នាំ៧៧ ក្រសួងរបស់ខ្ញុំបានបញ្ជូនខ្ញុំឲ្យមកធ្វើប្រវត្តិរូបនៅតាមខេត្តណាស់។

វណ្ណៈ៖ បាទ។

ដែន ៖ ឲ្យធ្វើប្រវត្តិរូបកងកំលាំងនៅក្នុងក្រសួងហ្នឹងឲ្យធ្វើប្រវត្តិរូបតាមខេត្តឲ្យចុះមកបានចំនួនពីរខេត្តមានខេត្តសៀមរាបនិងខេត្តកំពង់ធំ។

វណ្ណៈ៖ ចឹងពូមកឃើញទេសភាពតាមសហករណ៍យ៉ាងម៉េចទៅ?

ផែន ៖ ឃើញនៅតាមសហករណ៍ជួបការលំបាក បើមកខាងសៀមរាបនេះ ខ្ញុំជិះម៉ូតូចង់ចូលមកភូមិនេះ ឯង ចូលពីក្បាលដើមផ្លូវមកឃើញប្រជាពលរដ្ឋអង្គុយតាមផ្លូវព្រៀត តែឃើញម៉ូតូខ្ញុំមកបាត់អស់រលីង ។

វណ្ណៈ៖ ចឹង?

ផែនៈ បាទ ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូមានបានឃើញប្រជាជនអត់មែនឬមួយយ៉ាងម៉េច?

ផែន ៖ បាទ!អត់មែន ។

វណ្ណៈ៖ ចឹងនៅពេលពូបានឃើញចឹងពូមានអារម្មណ៍យ៉ាងម៉េចនៅពេលហ្នឹង?

ផែន ៖ ដល់ចឹងអារម្មណ៍ដូចជាខ្លោចផ្សារដែលអារម្មណ៍នោះ ។

វណ្ណៈ៖ ចឹងនៅពេលពូបានទៅដល់ភ្នំពេញវិញ ពូមានហ៊ាននិយាយប្រាប់គេទេ?

ផែន ៖ កាលហ្នឹងនៅខាងក្រសួងខ្ញុំគេមានផែនការឲ្យមកបង្ហូនមកលេងផ្ទះម្តងពីរឡានអា៩បាំង ។

វណ្ណៈ៖ នៅឆ្នាំណា?

ផែន ៖ នៅឆ្នាំ៧៧ ម្តងពីរឡានអា៩បាំង ចេញមកម្តងកន្លះខែ ។

វណ្ណៈ៖ ចឹងពូមានបានមកលេងផ្ទះទេ?

ផែន ៖ ខ្ញុំជូនដំណើរគេមក ខ្ញុំមកធ្វើប្រវត្តិរូបកងកំលាំងដែលនៅតាមខេត្តនោះផង ហើយក្នុងក្រសួងមុនគេឲ្យមកលេងផ្ទះគេឲ្យទៅរៀនសូត្របីថ្ងៃសិន ។

វណ្ណៈ៖ បាទ ។

ផែន ៖ គេឲ្យរៀនសូត្រហើយ គេឲ្យតាមដានជីវភាពប្រជាពលរដ្ឋ តាមដានពីរបៀបដឹកនាំប្រធានសហករណ៍ខាងក្រោយ ។

វណ្ណៈ៖ បាទ ។

ផែនៈ ឃើញជីវភាពប្រជាជនយ៉ាងណា នៅពេលដែលត្រឡប់ទៅវិញគេមិនទាន់ ឲ្យត្រឡប់ទៅកន្លែងទេ កងកំលាំងហ្នឹងទៅវិញគេហៅចូលសាលាមួយថ្ងៃសិនពីណាឃើញយ៉ាងម៉េចឲ្យឡើងរាយ ការណ៍ ។

វណ្ណៈ៖ ចឹងដល់ពេលឡើងរាយការណ៍ទៅយ៉ាងម៉េច?

ផែន ៖ ពីណារាយការណ៍អីរាយទៅ តែមិនដូចជាមិនឃើញមានអីទេ រាយទៅស្ងាត់ទៅមិនដឹងជាខាងលើគេមានផែនការយ៉ាងម៉េចខ្ញុំមិនដឹងដែរ ។

វណ្ណៈ៖ ចឹងអ្នកដែលរាយការណ៍ហើយមានបាត់ខ្លួនអីទេ?

ផែន ៖ ទេ ដូចជាមិនមានអីទេ ។

វណ្ណៈ៖ ចឹងនៅឆ្នាំ៧៨អីទៀតពូនៅខាងឃ្លាំងដដែលទេ?

ដែន ៖ បាទ!ខ្ញុំនៅខាងឃ្លាំងរហូតដល់រត់យួនតែម្តង ។

វណ្ណៈ៖ ចឹងកាលពូជាយោធាដំបូងដែលធ្លាប់វៃចូលទីក្រុងភ្នំពេញកាលហ្នឹងមានប៉ុន្មានកងពល?

ដែន ៖ ខ្ញុំក្តាប់មិនបានដែរ កាលគេដាក់ផែនការវៃទីក្រុងភ្នំពេញក្នុងកងវរៈសេនាតូចខ្ញុំហ្នឹង គេដកពួកខ្ញុំមួយក្រុមមកវៃនៅខាងទន្លេសាប ។

វណ្ណៈ៖ បាទ ។

ដែន ៖ មកវៃនៅខាងទន្លេសាបប្រហែលជាកន្លះខែ រួចទៅបានគេដកពួកខ្ញុំដែលនៅប្រចាំជុំវិញក្រុងហ្នឹងទៅវៃនៅភ្នំពេញ ដល់ខ្ញុំវៃខាងទន្លេសាបហើយខ្ញុំត្រឡប់ទៅកងខ្ញុំវិញ ពួកខ្ញុំហ្នឹងគេទៅភ្នំពេញអស់ បានជាប្រធានតំបន់នៅខាងកំពង់ធំហ្នឹងគាត់ថាមិនបាច់ទៅវិញទេ ចាំគាត់បង្កើតកងថ្មីឲ្យមួយកង ចឹងអត់បានទៅជាមួយគេក៏នៅប្រចាំកំពង់ធំនេះរហូត ។

វណ្ណៈ៖ ចឹងប្រវត្តិរូបយុវជននៅទីក្រុងភ្នំពេញហ្នឹងមិនមែនសួរតែនៅភ្នំពេញទេ គឺមានចុះសួរមកដល់ផ្ទះទៀត ។

ដែន ៖ បាទ ។

វណ្ណៈ៖ ចឹងក្រុមពូមានគំរោងចុះគ្រប់ខេត្តទាំងអស់ឬមួយយ៉ាងម៉េច?

ដែន ៖ គំរោងគេមិនដឹងជាយ៉ាងម៉េចទេ តែតាមគំរោងដែលឲ្យពួកខ្ញុំចុះទៅហ្នឹងមានបីខេត្តមានខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តកំពង់ចាម តែខ្ញុំធ្វើបានតែពីរខេត្តសភាពការណ៍វាមិនស្រួលទៅ ក៏ផ្អាកធ្វើទៅធ្វើបានតែពីរខេត្ត ។

វណ្ណៈ៖ ចឹងពីរខេត្តហ្នឹងមានបានធ្វើចប់ទេ?

ដែន ៖ ចប់ ។

វណ្ណៈ៖ ចឹងនៅពេលដែលធ្វើប្រវត្តិរូបតាមភូមិចប់ចឹង យើងយកទៅឲ្យពីណា?

ដែន ៖ យកទៅឲ្យមេខាងក្រសួងទៅ ។

វណ្ណៈ៖ មេហ្នឹងឈ្មោះអីទៅ?

ដែន ៖ ឈ្មោះរឿងហ្នឹង ។

វណ្ណៈ៖ ឈ្មោះ រឿង?

ដែនៈ បាទ ។

វណ្ណៈ៖ ចឹងរឿងហ្នឹងគាត់មានតួនាទីអី?

ដែន ៖ ប្រធានខាងក្រសួងឃ្លាំងរដ្ឋហ្នឹង ។

វណ្ណៈ៖ ចឹងរឿងហ្នឹងក្រោយមកគេចាប់គាត់ដែរឬមួយគេមិនបានចាប់គាត់ទេ?

ដែន ៖ មិនបានចាប់គាត់ទេ ។

វណ្ណៈ៖ ចឹងរាល់ថ្ងៃគាត់នៅរស់ដែលឬយ៉ាងម៉េច?

ដែន ៖ គាត់ស្លាប់ហើយនៅពេលដែលគាត់រត់មកខាងខេត្តនោះ គាត់ស្លាប់នៅទីនោះ ។

វណ្ណៈ៖ គាត់ស្លាប់ដោយសារអី?

ដែន ៖ គាត់ស្លាប់ដោយសារមានជំងឺទឹកនោមផ្អែម ។

វណ្ណៈ៖ ចឹងនៅពេល៧៩កាលដែលយួនចូលមកហេតុអីបានជាពូមិនរត់ទៅស្រុកកំណើតម៉េចបានរត់មកដាយដែននេះវិញ?

ដែន ៖ កាលហ្នឹងយើងវាក្តាប់មិនបានដែលណាស់ តែធម្មតាគេថ្នាក់លើនិយាយមកថាយួនវាចេះវាចុះនោះណាស់ ។

វណ្ណៈ៖ បាទ ។

ដែន ៖ ថាកាប់សម្លាប់ចេះចុះ កាលនោះបានកូនងើតអាមួយបងបានតែពីខែនោះ ទៅគេឲ្យគ្រួសារខ្ញុំចេញមកមុន ដល់ពេលនោះចេញមកតាមក្រោយ ខ្ញុំចេញមកតាមគ្រួសារខ្ញុំមកបានចេញផុតមកនេះមក ។

វណ្ណៈ៖ ចឹងកាលដែលពូរៀបការនៅឆ្នាំណា?

ដែន ៖ ឆ្នាំ៧៦ ។

វណ្ណៈ៖ កាលហ្នឹងមានប៉ុន្មានគូរ?

ដែន ៖ កាលហ្នឹងខ្ញុំការតែពីរគូរ ។

វណ្ណៈ៖ ចឹងតែពីរគូរទេ?

ដែនៈ បាទ ។

វណ្ណៈ៖ ចឹងកាលឆ្នាំ៧៩រត់បែកគ្នាទៀត?

ដែន ៖ ៧៩អត់រត់បែកទេ គ្រាន់តែចេញមកមុន ខ្ញុំមកតាមក្រោយមកទាន់គ្នានៅខេត្តកំពង់ស្ពឺជួបគ្នានៅឱរ៉ាល់ជួប ។

វណ្ណៈ៖ ចឹងបានជួបគ្នានៅកំពង់ស្ពឺ?

ដែនៈ បាទ ។

វណ្ណៈ៖ កាលនោះហ៊ានរត់តាមថ្នល់ទេ?

ដែន ៖ តាមថ្នល់កាលនោះមិនទាន់មានអីផង ។

វណ្ណៈ៖ បាទ ។

ដែនៈ មិនទាន់មានអីទេ ។

វណ្ណៈ  ចឹងរត់តាមថ្នល់ខ្វះកាត់ព្រៃខ្វះទៅ?

ដែនៈ  បាទ!  រត់តាមថ្នល់ខ្វះ តែតាមថ្នលវាឃើតមនុស្សវាច្រើននោះមានឡានផងអីផង ។

វណ្ណៈ  ចឹងតាមពូដឹងថាមនុស្សដែលរត់ទំរាំមកដល់ជាយដែននេះមានមនុស្សស្លាប់ច្រើនទៀតទេ?

ដែន ៈ  តែបើតាមផ្លូវខ្ញុំមកមិនមានជួបខបគ្គ័សអីទេ ។

វណ្ណៈ  បាទ ។

ដែនៈ  រត់ពីភ្នំពេញមកដល់ភ្នំឱរ៉ាលសម្រាកចង់មួយខែ ។

វណ្ណៈ  បាទ ។

ដែន ៈ  ប្រុសតែធ្វើផ្ទះនៅហ្នឹងហើយ  ធ្វើផ្ទះបានបួន១០ខ្នងហើយ ។

វណ្ណៈ  បាទ ។

ដែនូ  ផ្ទះតូចៗដល់វៀតណាមបុកមកទៀតដកពីហ្នឹងមកដល់លាច ។

វណ្ណៈ  បាទ ។

ដែនៈ  ឆ្លងភ្នំឱរ៉ាលមកលាចចេញពីលាចមកធ្លាក់ដល់តាឡូ  មកដល់ភ្នំធិបដេបានធ្លាក់មកដល់បវេល ។

វណ្ណៈ  កាលរត់កាត់ព្រៃពូមានឃើញរណ្តៅសាកសពថ្មីៗ  ពូរត់មកមានជួបទេ?

ដែន ៈ  កាលរត់មកដល់ស្រុកបវេលនេះបានឃើញខ្វះ  ឃើញថ្មីៗទើបតែស្អុយ ។

វណ្ណៈ  បាទ ។

ដែនៈ  ទំនងទើបនិងងាប់នៅពេលវៀតណាមចូលមកហើយមនុស្សមានកំហឹងនិងគ្នាណាស់ ។

វណ្ណៈ  បាទ ។

ដែនៈ  ដល់មានកំហឹងនិងគ្នាកាប់គ្នាវៃគ្នា ។

វណ្ណៈ  ចឹងកាលដែលពូរត់កាត់ព្រៃមកប្រើរយៈពេលប៉ុន្មានខែប៉ុន្មានអាទិត្យដែលបានមកដល់ព្រំដែនតែម្តង?

ដែន ៈ  ដូចជាមិនចាំទេ  មើលមកពីនោះមក ។

វណ្ណៈ  ចេញមកពូថានៅឱរ៉ាលមួយខែ?

ដែនៈ  នៅឱរ៉ាលមិនដល់មួយខែទេជិតមួយខែ ។

វណ្ណៈ  ចឹងចេញពីឱរ៉ាលមកទៀត?

ដែនៈ  មកនៅបវេលហ្នឹងជិតមួយខែទៀត ។

វណ្ណៈ  ចុះទំរាំមកដល់ម៉ាឡៃ?

ដែនៈ  មើលទំរាំមកដល់ម៉ាឡៃនេះខែ១១យើងចាប់ផ្តើមរត់ ។

វណ្ណៈ  កាលរត់នៅខែ១មករា  ៧មករា?

ដែនៈ ៧មករា ។

វណ្ណៈ ចឹងខែ១ប៉ុន្មានខែបានមកដល់នេះ?

ដែនៈ អត់ទេ ៧មករាហ្នឹងតាមមើលគេកំណត់យកថ្ងៃហ្នឹងតែម្ដង ។

វណ្ណៈ បាទ ។

ដែនៈ ចាប់ផ្ដើមរត់ពីភ្នំពេញតាំងពីខែ១១ខ្ញុំចំណាំមែន ចុងខែ១១ ។

វណ្ណៈ ចឹងចុងខែ១១នៅឆ្នាំណា?

ដែនៈ ឆ្នាំ៧៩ហ្នឹង ។

វណ្ណៈ អត់ទេ ខុសហើយព្រោះចុងខែ១១នៅឆ្នាំ៧៨នៅឡើយហ្នឹង ដល់ខែ១២ខែ១បានចូល៧៩តែម្ដង?

ដែនៈ តែខ្ញុំចំណាំរត់ខែ១១ ។

វណ្ណៈ អាចថាថ្ងៃ១១?

ដែនៈ មិនមែនថ្ងៃ៧ទេ ដូចជាខែ១១តែម្ដងខ្ញុំចំណាំ ។

វណ្ណៈ បើខែ១១មិនទាន់ចូល៧៩ទេ នៅ៧៨នៅឡើយប៉ុល ពតនៅពេញនៅឡើយទេ មិនទាន់រត់ទេកាលហ្នឹង?

ដែនៈ ចាប់ផ្ដើមរត់ចេញពីភ្នំពេញហែរៗមកខ្ញុំចំណាំថាខែ១១ ។

វណ្ណៈ ចឹងរត់តាំងពី៧៨ម្ល៉េះ?

ដែនៈ បាទ!ទំនងរត់តាំងពី៧៨ខែ១១ម៉េះ ។

វណ្ណៈ ចឹងហេតុអីបានជារត់មុនដល់រាប់ខែនោះ កាលហ្នឹងសម្ដេចសីហនុក៏មិនទាន់ចេញដែរ សម្ដេចសីហនុចេញនៅឆ្នាំ៧៩ដែរមុន៧មករាហ្នឹងបីថ្ងៃទេ គាត់នៅក្នុងវាំង ចឹងខ្ញុំជឿថាទាហាននិងកងកំលាំងមិនអាចចេញមុនគាត់បានទេ អាចថាពូច្រឡំថ្ងៃទៅជាខែវិញ ចឹងគិតចេះវិញពូគិតថាយួនចូលមកហើយឬមិនទាន់ចូលមកទេ?

ដែនៈ យួនចូលមកហើយ ។

វណ្ណៈ ចឹងមានតែរត់ឆ្នាំ៧៩ហើយ?

ដែនៈ បាទ ។

វណ្ណៈ ចឹងគ្រាន់តែចង់ដឹងថាចំណាយពេលពីរទៅបីខែឬមួយយ៉ាងម៉េច?

ដែនៈ ពីរបីខែ ។

វណ្ណៈ ចឹងប្រហែលជាបីខែ?

ដែនៈ បាទ!មកដល់ព្រំដែនហ្នឹងឆ្នាំ៨០ហើយ ។

វណ្ណៈ  ចឹងប៉ុន្មានខែហ្នឹងពូនៅកន្លែងណាខ្លះ?

ដែន  :  ចេញពីភ្នំពេញមកនៅឪរ៉ាល  ចេញពីឪរ៉ាលមកនៅបវេល ។

វណ្ណៈ  បាទ ។

ដែនៈ  ចេញពីបវេលមកនៅតាគង់ចេញពីតាគង់ ។

វណ្ណៈ  ចឹងនៅច្រើនកន្លែង?

ដែនៈ  បាទ! បានចេញពីតាគង់បានមកដល់នេះ  មកដល់នេះហើយនៅមិនស្ងៀមទៀតរត់តាមផ្លូវនេះមកដល់នេះ  ទៅពីនេះទៅនៅដល់គ្រាង ។

វណ្ណៈ  បាទ!ដល់គ្រាង ។

ដែនៈ  ទៅនៅគ្រាង  វៀតណាមបុកគ្រាងរត់ពីគ្រាងមកនៅម្តុំភ្នំព្រឹក ។

វណ្ណៈ  ភ្នំព្រឹក?

ដែនៈ  បាទ!ភ្នំព្រឹកគេហៅភ្នំ៥៣នោះ ។

វណ្ណៈ  បាទ ។

ដែនៈ  ភ្នំព្រឹករត់ពីនោះមកនេះវិញទៀត ។

វណ្ណៈ  តាំងនៅចក្រីតាំងម៉ាឡៃ  ពូគិតថាកាលហ្នឹងព្រៃតែនគាប់ព្រៃច្រើនប៉ុយ៉ាងម៉េច?

ដែន  :  កាលនោះព្រៃទាំងអស់តែម្តង  ឲ្យតែខ្សែព្រំដែនព្រៃទាំងអស់គ្មានវាលទេ  បើខែនេះគួកខោអាវហាលមិនស្ងួតទេ  ទាល់តែដុតភ្លើងឆ្អើរនៅក្នុងព្រៃ ។

វណ្ណៈ  ចឹងកាលហ្នឹងពូយើងដើរកាត់ព្រៃយប់ថ្ងៃអី  មានជួបសត្វធំៗទេ  មានដំរីខ្លាឬមានសត្វអីផ្សេងៗទេ?

ដែន  :  ដូចជាមិនមានជួបព្រោះមនុស្សវាច្រើន ។

វណ្ណៈ  បាទ ។

ដែនៈ  វាផ្អើលអស់មិនមានជួបទេ ។

វណ្ណៈ  តែដឹងថាមានសត្វធំៗទេ?

ដែន  :  មាន  ដឹងថាមានព្រោះមានឃើញគ្រលងអី ។

វណ្ណៈ  ដូចថាឆ្នាំ៨០អីចឹងកាលដែលពូមកនៅទីនេះ  ពូនៅជាកងកំលាំងវៃជាមួយយួនដែលឬមួយពូនៅសមរភូមិក្រោយបើពូមានគ្រួសារហើយចឹង?

ដែន  :  ខ្ញុំមកដល់ក្នុងនេះ  ខ្ញុំនៅមេភូមិឈប់រត់កើតភូមិនៅហើយណាស់  តែកាលហ្នឹងដឹកជញ្ជូនត្រៀមដូចតែគេដែលទេ ។

វណ្ណៈ  ចឹងពូមានប្រពន្ធកូនហើយឆ្នាំ៨០-៨១-៨២-៨៣ហ្នឹងចឹងយើងអ្នកដឹកសម្ភារទៅកងទ័ព?

ដែនៈ   ដឹកសម្ភារទៅកងទ័ពឬទៅជួយត្រៀមកងទ័ពនៅកន្លែងណាផ្សេងៗ ។

វណ្ណៈ  ចឹង?

ដែនៈ   បាទ ។

វណ្ណៈ  ចឹងកាលហ្នឹងខាងកងទ័ពមានប្រាក់ខែទេ?

ដែន ៈ អត់មានទេ ។

វណ្ណៈ  ចឹងមកដល់ឥឡូវពូមានបានប្រាក់បៀវត្សសន្តមកិច្ចអីទេ?

ដែនៈ   សព្វថ្ងៃនេះ ។

វណ្ណៈ  បាទ ។

ដែន ៈ កាលពីឆ្នាំ៨២ដល់ឆ្នាំ៩៦  ខ្ញុំនៅកងពលខាងនោះ ។

វណ្ណៈ  កងពលពីណាគេ?

ដែនៈ   កងពល៣២០ខាងនោះជាមួយតា  កន ។

វណ្ណៈ  ចឹងតា  កនកាន់កងពល៣២០?

ដែនៈ   បាទ ។

វណ្ណៈ  ចឹងតា  កនសព្វថ្ងៃគាត់នៅដែរ?

ដែន ៈ នៅ ។

វណ្ណៈ  ចឹងតា  កនហើយមានពីណាទៀត?

ដែនៈ   មកដល់ឆ្នាំ៨២ខ្ញុំរត់ពី៣២០ខ្ញុំរត់មកនៅអីនេះ ។

វណ្ណៈ  នៅហ្នឹងពីណាគេវិញ?

ដែនៈ   នៅនេះសួរ  ហុង ។

វណ្ណៈ  សួរ  ហុង?

ដែនៈ   បាទ ។

វណ្ណៈ  នៅកងពលប៉ុន្មាន?

ដែនៈ   កងពល៥៥០ ។

វណ្ណៈ  ៥៥០?

ដែនៈ   បាទ ។

វណ្ណៈ  មិនមែន៤៥០ទេ?

ដែនៈ   អ!៤៥០មិនមែន៥៥០ទេ ។

វណ្ណៈ  ចឹងតាកនគាត់នៅខាងចក្រី?

ដែន ៖ បាទ ។

វណ្ណៈ៖ ចឹងតា ហុង គាត់នៅកាន់កងពលខាងម៉ាឡៃ?

ដែន ៖ ខាងម៉ាឡៃ ។

វណ្ណៈ៖ ចឹងក្រោយពីតា ហុងមកមានលោកសុខ ភាពចឹងទៅ?

ដែនៈ ដល់ពេលមកខាងតា ហុងនេះដល់នេះទៅបង ហុងគាត់ទទួលពីរសមរភូមិ ។

វណ្ណៈ៖ បាទ ។

ដែនៈ គាត់ទទួលកងពល៥១៩មួយកងពលទៅនៅខាងភ្នំដងរែកនោះ ហើយមកខាងនេះកងពល ៤៥០ទៀតគាត់ទទួលពីរកងពល ។

វណ្ណៈ៖ បាទ ។

ដែន ៖ ហើយកងពល៤៥០នេះមានលោកសុខ ភាព អ្នកទទួលកងពល៥១៩នោះបងសារឿន ចឹង បងហុងគាត់ទទួលកងពលទាំងពីរ គេហៅថាគណៈសមរភូមិ ។

វណ្ណៈ៖ ចឹងមានន័យថា តា ហុងធំជាងតា សុខ ភាពទៀត ព្រោះគាត់កាន់ពីរកងពល?

ដែន ៖ ធំជាង ព្រោះគាត់កាន់ពីរកងពលនោះ ។

វណ្ណៈ៖ ចឹងតាហុង គាត់កាន់កងពល៤៥០ផងនិងកងពលណាទៀត?

ដែន ៖ កងពល៥១៩ ។

វណ្ណៈ៖ ចឹងតាហុងសព្វថ្ងៃគាត់នៅរស់ដែរ?

ដែន ៖ គាត់នៅរស់ ។

វណ្ណៈ៖ ចឹងសព្វថ្ងៃគាត់រស់នៅម៉ាឡៃហ្នឹងដែរ?

ដែន ៖ ទេ ខ្ញុំមិនដឹងជាគាត់ទៅនៅណាទេ តែផ្ទះគាត់នៅហ្នឹងមួយ តែមិនថានៅណាទៀតទេ ។

វណ្ណៈ៖ ចឹងពល់ថ្ងៃតា សុខ ភាពគាត់ធំជាង?

ដែន ៖ បាទ !តា សុខ ភាពធំជាងហើយ ។

វណ្ណៈ៖ គាត់ចូលទៅជាមួយរដ្ឋាភិបាល?

ដែនៈ បាទ!កាលមុនគាត់ខាងភូមិភាគ៥ដែរ ។

វណ្ណៈ៖ ចឹងខ្ញុំចង់ដឹងថា នៅក្រោយសម័យ៧៩ហ្នឹងមានព្វថាមានចង់ប្រមូលរបស់របរដាក់រួមទៀតមែន ឬមួយយ៉ាងម៉េចដែរ?

ដែន ៖ រឿងហ្នឹងដាក់រួមមិនមែនដូចសម័យមុនទេ ។

វណ្ណៈ បាទ ។

ដែនៈ កន្ទួងមកពីណារកស៊ីបានខ្វះទិញឡាន ខ្វះទិញត្រាក់ទ័រ ។

វណ្ណៈ   បាទ ។

ដែនៈ   តែដល់ក្រោយមក ។

វណ្ណៈ   ប្រហែលជាឆ្នាំណា?

ដែនៈ   មកឆ្នាំមុនយើងសមាហរណកម្មនេះ ។

វណ្ណៈ   ចឹងឆ្នាំ៩០ជាងហើយហ្នឹង?

ដែនៈ   បាទ!មុនយើងសមាហរណ៍កម្មប្រហែលជាមួយឆ្នាំអីទេ ។

វណ្ណៈ   ចឹងឆ្នាំ៩៥?

ដែនៈ   ក្នុងនោះគេប្រមូលកំលាំងមិនបានទៅមុខ ។

វណ្ណៈ   បាទ ។

ដែន :   មនុស្សរើករកស៊ី ចឹងទៅអ្នកណាមានឡាន មានអាគ្រាក់គេដកទុកមួយកន្លែង ។

វណ្ណៈ   កាលហ្នឹងមានប្រមូលបានហើយឬនៅ?

ដែន :   បាន ។

វណ្ណៈ   ពេលប្រមូលមានអីខ្លះ?

ដែន :   កាលហ្នឹងមានឡាន អាគ្រាក់ ។

វណ្ណៈ   ចឹងម៉ូតូគោរទេះអី?

ដែន :   អត់មានទេ គោមិនទាន់ប្រមូលទេ តែដល់ក្រោយមកចង់ដកគោទៀត កាលនោះម៉ូតូអីមិនទាន់ទេ មិនទាន់មានផ្លូវអី ។

វណ្ណៈ   ចឹងមិនទាន់មានម៉ូតូកាលហ្នឹង?

ដែនៈ   បាទ ។

វណ្ណៈ   ចឹងប្រជាជនអត់មានប្រត្តិកម្មតវ៉ាអីទេ?

ដែន :   ប្រត្តិកម្មរឿងហ្នឹងឯងបានរើបំរះកងពលយើងនេះ ត្រឹមកងពល៤៥០និងខាងប៉ៃលិនរើបំរះប្រឆាំង ចឹងបានជាខាង៤៥០និងខាងប៉ៃលិនសមាហរណ៍កម្មចូលខាងរដ្ឋាភិបាលទៅ ។

វណ្ណៈ   បាទ ។

ដែន :   រឿងហ្នឹងឯងប្រមូលរបស់របរហើយចង់ប្រមូលទេះគោទៀតនោះ ។

វណ្ណៈ   ចឹងមានពុថាចង់បង្កើតសហករណ៍ទៀតទេ?

ដែន :   ដូចជាមិនមានពុថាបង្កើតទេ ។

វណ្ណៈ   តែជាគោលដៅ?

ដែនៈ   បាទ ។

វណ្ណៈ  ចឹងពូមានដឹងទេថាពីណាជាអ្នកមានគំនិតឲ្យប្រមូល?

ដែន  :  មានបញ្ជាពីលើមកតែម្តង  មិនដឹងពីថ្នាក់ណាមក  តាមមើលជាគំនិតសុន  សេន ។

វណ្ណៈ  ហ្នឹងហើយសុន  សេនគេនិយាយចឹងដែរ?

ដែនៈ  បាទ!  ព្រោះកាន់ខាងកងទ័ពសុន  សេនហើយ ។

វណ្ណៈ  ចឹងសុន  សេនគាត់កាចទេ  តាមពូឃើញគាត់?

ដែន  :  ខ្ញុំសុន  សេនដូចជាមិនដែលបានធ្វើការជួប ។

វណ្ណៈ  បាទ ។

ដែនៈ  ព្រោះគាត់កាន់ខាងកងទ័ពតាំងពីពន្លាំមករហូតមក ។

វណ្ណៈ  បាទ ។

ដែនៈ  ដូចនេះខ្ញុំនៅក្រៅកងទ័ពមិនដែលបានធ្វើការជាមួយ ។

វណ្ណៈ  តែនៅម៉ាឡៃនេះតំបន់ហ្នឹងលោកតា  អៀង  សារីគាត់ជាអ្នកទទួលខុសត្រូវ?

ដែន  :  បាទ!តា  អៀង  សារីគាត់ទទួលខុសត្រូវតំបន់ម៉ាឡៃនេះ ។

វណ្ណៈ  តែសុន  សេនចេញចូលមកធ្វើការមកបញ្ជាបាន?

ដែន  :  បាទ ។

វណ្ណៈ  ចឹងតា  ប៉ុល  ពតមានមកទេ?

ដែន  :  មិនដែលមកទេ ។

វណ្ណៈ  ចឹងកាលសម្តេចសីហនុចុះមកដល់សារគាំងអីហ្នឹងពូមានបានមកទាន់ទេ?

ដែន  :  ទាន់ ។

វណ្ណៈ  ចឹងពូមានបានមកឃើញសម្តេចទេ?

ដែន  :  ខ្ញុំមិនដែលបានមកហ្នឹងគេទេ  នៅខាងមុខ ។

វណ្ណៈ  ចឹងគ្រាន់តែបានដឹង?

ដែន  :  បាទ!គ្រាន់តែដឹង ។

វណ្ណៈ  ចឹងពូមានដឹងរឿងរ៉ាវសុន  សេនគេបាញ់សម្លាប់គាត់នៅឆ្នាំណាពូមានដឹងទេ?

ដែន  :  ទេ  មិនបានដឹងទេ  តែឮៗទៅសុន  សេនស្លាប់នោះ ។

វណ្ណៈ  មិនមែនស្លាប់នៅម៉ាឡៃទេ?

ដែន  :  អត់ទេ  ស្លាប់នៅអន្លង់វែង ។

វណ្ណៈ  ស្លាប់នៅអន្លង់វែង?

ដែនៈ  បាទ!  មិនដឹងស្លាប់នៅត្រង់ៗតែឮគេនិយាយ ។

វណ្ណៈ  ចឹងសុន  សេនស្លាប់ហ្នឹងមូលហេតុមកពីគាត់ប្រឆាំងឲ្យមានការដាក់រូបចឹងឬមួយយ៉ាងម៉េច?

ដែន  :  ខ្ញុំមិនបានដឹងដែរនៅឆ្ងាយ ។

វណ្ណៈ  ចឹងពូមានបានដឹងថា  លោកសុន  សេននិងលោក  ខៀវ  សំផនហ្នឹងគាត់បានទៅចរចារជាមួយរដ្ឋាភិបាលហើយពេលហ្នឹងតា  ខៀវ  សំផនត្រូវគេគប់និងដុំថ្មអីចឹង  ចំណែកសុន  សេនមិនបានទទួលរងគ្រោះអីទេ  ចឹងនៅពេលមកវិញមានរឿងរ៉ាវអីកើតឡើងខ្លះពេលហ្នឹង  ពូមានបានដឹងរឿងខ្លះដែរ?

ដែន  :  រឿងហ្នឹងខ្ញុំមិនបានដឹងផង ។

វណ្ណៈ  ចឹងអត់មានបានដឹងទេ?

ដែនៈ  បាទ!  ចឹងពេលគប់នៅភ្នំពេញនោះ ។

វណ្ណៈ  បាទ!គប់នៅភ្នំពេញកាលហ្នឹងសុន  សេនមិនមានរងគ្រោះដូចខៀវ  សំផនទេ?

ដែន  :  ខ្ញុំមិនដឹងថាសុន  សេនបានទៅភ្នំពេញផង ។

វណ្ណៈ  ចឹងពូមិនបានដឹងក៏មិនអីទេ  តែមានគេដឹងថាទៅជាមួយគ្នាប៉ុន្តែខៀវ  សំផនគ្រោះថ្នាក់  សុនសេនមិនគ្រោះថ្នាក់ ។

ដែន  :  ខ្ញុំមិនដឹងដែរ ។

វណ្ណៈ  ចឹងមិនបានដឹងទេរឿងរ៉ាវហ្នឹង?

ដែនៈ  បាទ ។

វណ្ណៈ  ចឹងកងកំលាំងខ្មែរក្រហមហ្នឹងតស៊ូរហូតពេលអ៊ុនគាត់ចូលនៅឆ្នាំ១៩៩២មានអ៊ុនគាត់ចូលមកដល់នេះទេ?

ដែន  :  អត់មានចូលមកដល់នេះទេ ។

វណ្ណៈ  ចឹងអ៊ុនគាត់គ្មានចូលមកដល់នេះទេ?

ដែនៈ  បាទ ។

វណ្ណៈ  ចឹងនៅខាងខ្មែរក្រហមហ្នឹងមិនបានចូលរួមបោះឆ្នោតទេ?

ដែន  :  បាទ!អត់មានបានបោះឆ្នោតទេ ។

វណ្ណៈ  កាលហ្នឹងពូមានចិត្តចង់បោះឆ្នោតដែលឬមួយយ៉ាងម៉េច?

ដែន  :  កាលហ្នឹងគេថា  មិនឲ្យបោះមិនដឹងជាធ្វើយ៉ាងម៉េច ។

វណ្ណៈ  ហ្នឹងហើយ?

ដែនៈ  បាទ!បើយើងរស់នៅក្រោមបញ្ជារបស់គេ ។

វណ្ណៈ ចឹងក្រោយៗមកទៀតតាមពូដឹងពូនៅហ្នឹងរហូតនៅពេលព្រៃឈើដែលអស់ ចាប់អស់ហ្នឹងពូគិតថានៅឆ្នាំណាដែលអស់ក្លាយជាដីចំការចឹងទៅ?

ដែន ៖ អស់មែនទែន ។

វណ្ណៈ បាទ ។

ដែនៈ វាកាលហ្នឹងកាប់ហែរៗចឹងទៅ កាប់ទៅពីនេះហែរៗ ។

វណ្ណៈ ចឹងដើមឈើធំៗអស់នៅពេលណា?

ដែន ៖ ដើមឈើធំៗកាប់អារលក់ ។

វណ្ណៈ អារលក់ទៅខាងថៃអីចឹងទៅ?

ដែនៈ លក់ទៅថៃខ្លះខ្មែរខ្លះ ។

វណ្ណៈ ចឹងកាលហ្នឹងកូនទាហានតូចៗអីមានសិទ្ធកាប់ទេ?

ដែន ៖ តែបើអារឈើធ្វើផ្ទះលក់ធម្មតាបាន តែអារជាគ្រឿងចឹងមកលក់បាន តែបើលក់ទាំងដើមដឹកចេញទៅមិនមានទេ ។

វណ្ណៈ អាហ្នឹងទាល់តែមេៗធំៗ?

ដែនៈ អាហ្នឹងទាល់អ្នកធំមានមុខមានមាត់ ។

វណ្ណៈ ចឹងហើយគេធំមានសិទ្ធជាងយើង?

ដែនៈ បាទ! តែយើងអារចេញជាគ្រឿងជាក្តារចេះលក់បាន លក់តាមច្រកអូរចេះទៅ ។

វណ្ណៈ ចឹងថៃវាមកទិញ?

ដែនៈ ថៃវាមកទិញ ។

វណ្ណៈ ចឹងយើងលក់បានដែលមិនអីទេ?

ដែនៈ បាទ ។

វណ្ណៈ ចឹងនៅពេលប្រជាជនចាប់ផ្តើមកាប់ព្រៃអីចឹង កាប់មុនសមាហរណ៍កម្មឬក្រោយសមាហរណ៍កម្ម?

ដែន ៖ ចាប់ផ្តើមកាប់តាំងពីមុនហ្នឹងទៀត ។

វណ្ណៈ មុន?

ដែនៈ មុនសមាហរណ៍កម្មហែរៗតែវាបានជិតល្មម ។

វណ្ណៈ ចឹងជិតល្មមទេ?

ដែនៈ បាទ ។

វណ្ណៈ កាលហ្នឹងព្រៃថាមានមីនច្រើន?

ដែន ៖ មិនមានច្រើនហើយប្រជាជននៅទីនេះ មិនមែនជាប្រជាជនធម្មតាសុទ្ធតែកងទ័ព ដូចនេះមិនដូចថាទៅត្រង់មុខសញ្ញាពីណាគេធ្លាប់ទៅគេដឹងថាកន្លែងនេះមានមីនកន្លែងនេះមិនមានមីនកន្លែងណាមីនគេរំលងចោលទៅគេទៅកាប់កន្លែងអត់មីនទៅ គេអ្នកដឹង ។

វណ្ណៈ៖ ចឹងនៅមានមនុស្សគ្រោះថ្នាក់ទេ?

ដែន ៖ មាន គ្រោះថ្នាក់នៅតែមានហ្នឹង ។

វណ្ណៈ៖ ចឹងមីនហ្នឹងដាក់តែខាងខ្មែរក្រហមឬទ័ពខាងក្នុងគេដាក់ដែរ?

ដែន ៖ ដាក់ទាំងអស់តែគ្នាហ្នឹង ខាងខ្មែរក្រហមក៏ដាក់ខាងក្នុងក៏ដាក់ ។

វណ្ណៈ៖ ចឹងនៅពេលដែលបងប្អូនខាងខ្មែរក្រហមហ្នឹងដឹងថាចូលសមាហរណ៍កម្មហ្នឹង មានបងប្អូនខ្លះភ័យមានអ្នកខ្លះមិនពេញចិត្តហ្នឹងការចូលមានអ្នកខ្លះសប្បាយឬមួយយ៉ាងម៉េចដែរ?

ដែន ៖ ភាគច្រើនគឺសប្បាយ ។

វណ្ណៈ៖ ភាគច្រើនសប្បាយ?

ដែន៖ បាទ!ទាំងគេទាំងខ្ញុំទាំងអស់លែងពិបាក ។

វណ្ណៈ៖ ព្រោះចប់សង្គ្រាមហើយ?

ដែន៖ បាទ ។

វណ្ណៈ៖ ចឹងពូគិតទៅប្រៀបធៀបមកឥឡូវហើយកាល៧៩ដល់៩៥ហើយពីសមាហរណ៍កម្មមកដល់បច្ចុប្បន្ននេះ ពីថាការរស់នៅរបៀបនេះហើយទៅពីមុនតើមួយណាស្រួលជាង?

ដែន ៖ ធ្វើម៉េចដល់យើងសព្វថ្ងៃ បើសព្វថ្ងៃយើងមានពេលរកហើយយើងចង់ហូបអីយើងរកបានយើងហូបហ្នឹងទៅ ។

វណ្ណៈ៖ យើងមានទីផ្សារសេរី?

ដែន ៖ បាទ!ទីផ្សារសេរី ។

វណ្ណៈ៖ យើងរកបានច្រើនហូបច្រើនយើងរកបានតិចហូបតិច?

ដែន៖ បាទ! បើយើងខ្ជិលរកក៏អត់ទៅបន្ទោសអ្នកណាបាន ។

វណ្ណៈ៖ តែកាលនោះយើងកាន់កាំភ្លើងដឹងថាបានហូប?

ដែន ៖ យើងកាន់កាំភ្លើងដឹងថាបានហូប តែវាមិនបាននេះទេ វាបានតែបាយហូបវាបានតែខោអាវកំណត់ថាមួយឆ្នាំប៉ុន្មានចឹងទៅ រឿងម្ហូបចំណីក្រៅៗវាមិនមានទេ យើងទៅរកណាបានបើយើងនៅចុះហ្នឹង ។

វណ្ណៈ៖ បើចង់មានអាគ្រាក់ម៉ូតូឡានអីអត់មានទេ?

ដែន ៖ អត់មានទេ ។

វណ្ណៈ  តែឥឡូវយើងបាន?

ដែនៈ  បាទ! ឥឡូវយើងមានលុយចង់ទិញអីក៏បាន ឲ្យតែរបស់ស្របច្បាប់កុំឲ្យតែរបស់ខុសច្បាប់ ។

វណ្ណៈ  ចឹងពូនៅជំនាន់ខ្មែរក្រហមពូមានបាត់បង់សាច់ញាតិអីខ្លះទេឬមួយមិនមានទេ បងប្អូនបង្កើត?

ដែន :  ខ្ញុំមានបងប្អូនបង្កើតស្លាប់មួយដែរ ។

វណ្ណៈ  ឈ្មោះអីគេ?

ដែន :  ឈ្មោះដុស ។

វណ្ណៈ  គាត់មានកំហុសអី?

ដែន :  ទេ កាលហ្នឹងគេហៅទៅលើកការដ្ឋាននៅខាងលើនោះក៏កើតជំងឺគ្រុនចាញ់ដល់មកដល់ផ្ទះវិញស្លាប់ទៅ ។

វណ្ណៈ  ចឹងស្លាប់ដោយសាគ្រុន?

ដែនៈ  បាទ ។

វណ្ណៈ  ចុះឪពុក?

ដែន :  អត់អីទេនៅ ។

វណ្ណៈ  ចឹងម្ដាយ?

ដែន :  ម្ដាយនៅស្លាប់ដោយសារជំងឺក្រោយមកទៀតទេ ។

វណ្ណៈ  ចឹងកាលពូចុះទៅធ្វើប្រវត្តិរូបនៅតាមជនបទឃើញប្រជាជនហូបចុកអត់ឃ្លានលំបាកអីចឹង តែខាងយោធាកម្មករនៅភ្នំពេញបានហូបចុកគ្រប់គ្រាន់មែនចឹង?

ដែន :  បាទ ។

វណ្ណៈ  ចឹងពូការខុះចន្លោះដែលថ្នាក់លើធ្វេសប្រហែសឬយ៉ាងម៉េចបានជាធ្វើឲ្យប្រជាជនស្លាប់ហ្នឹងពូគិតថានេះជាបន្ទុកថ្នាក់លើមិនមើលការខុសត្រូវឬក៏ជាថ្នាក់ក្រោមដែលធ្វើឲ្យប្រជាជនស្លាប់ច្រើនចឹងបើតាមពូគិតជាគំនិតរបស់ពូជាយោបល់?

ដែន :  តាមខ្ញុំយល់របបផ្ដាច់ការ ។

វណ្ណៈ  បាទ ។

ដែន៖  ដូចនេះអ្វីៗទាំងអស់នៅលើតែមនុស្សម្នាក់ ។

វណ្ណៈ  បាទ ។

ដែនៈ  ហើយការដឹកនាំសង្គមអង្គការបីហ្នឹង វាអត់មានឯករាជ្យ ។

វណ្ណៈ  អង្គការបីយ៉ាងម៉េចទៅ?

ដែន :  អង្គការតុលាការ អង្គការនិត្តិបញ្ញត អង្គការនិត្តិប្រត្តិប័ត្រវាអត់មានឯករាជ្យ ។

វណ្ណៈ៖ បាទ ។

ដែនៈ វានៅក្រោមការគ្រប់គ្រងទៅលើមនុស្សតែម្នាក់ហ្នឹងឯង ។

វណ្ណៈ៖ បាទ ។

ដែនៈ ដូច្នេះធ្វើក៏ដោយសម្រេចតែលើមនុស្សម្នាក់ ។

វណ្ណៈ៖ បាទ ។

ដែនៈ ដូចនេះការស៊ើបអង្កេតការតាមដានពីសកម្មភាពផ្សេងៗវាអត់មានអីទាំងអស់ ។

វណ្ណៈ៖ បាទ ។

ដែនៈ ដូចនេះអ្នកណាធ្វើអីក៏បានរហូតដល់មេក្រុមមេសហករណ៍ក៏អាចសម្រេចជីវិតមនុស្សបានដែរ ។

វណ្ណៈ៖ ចឹងពូគិតថ្នាក់កំពូលមិនបានយកចិត្តទុកដាក់?

ដែន ៖ បាទ ។

វណ្ណៈ៖ ថ្នាក់លើមានអំណាចផ្តាច់ការ?

ដែន ៖ បាទ ។

វណ្ណៈ៖ ចឹង តុលាការយើងមានមិនមែនតុលាការយើងសុទ្ធទេ មានអន្តរជាតិចូលរួមមានន័យថាអ្នកប្រព្រឹត្តអំពើខុសឆ្គងធ្វើឲ្យប្រជាជនស្លាប់ជាងមួយលាននាក់ ចឹងវាខុសហ្នឹងច្បាប់អន្តរជាតិដែលបានព្រមព្រៀងគ្នានៅឆ្នាំ៥០ជាង ចឹងអ្នកដែលទទួលខុសត្រូវធ្វើឲ្យមានមនុស្សស្លាប់ច្រើនចឹង ដូចនេះត្រូវមានតុលាការអន្តរជាតិចូលរួមដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមធំៗប៉ុន្មានរូបហ្នឹងណាស់ចឹងពូគិតថាមានតុលាការជាការត្រឹមត្រូវឬពូគិតថាមិនចាំបាច់មានតុលាការអីទេ ចឹងជាគំនិតរបស់ពូគិតថា មានតុលាការល្អឬមិនល្អ?

ដែន ៖ តាមគំនិតខ្ញុំគិតថា ប្រទេសរបស់យើងជាសមាជិករបស់អង្គការសហប្រជាជាត ។

វណ្ណៈ៖ បាទ ។

ដែនៈ ដូច្នេះមានជាការល្អដែរតែការសម្រេចអីហ្នឹង រដ្ឋាភិបាលយើងក៏មិនបណ្តោយការសម្រេចទៅតាមគេពេក ។

វណ្ណៈ៖ បាទ ។

ដែនៈ បើយើងអាកាត់ថាមិនឲ្យនេះក៏បានព្រោះនៅក្នុងប្រទេសរបស់យើង ។

វណ្ណៈ៖ ចឹងចំពោះបញ្ហាតុលាការពូអត់មានរឿងអីជំទាស់ទេ?

ដែន ៖ បាទ ។

វណ្ណៈ ព្រោះប្រទេសមានច្បាប់?

ដែនៈ បាទ!ប្រទេសមានច្បាប់ ។

វណ្ណៈ៖ ចឹងកាលពីឆ្នាំ៧៩ដល់ឆ្នាំ៨០ដាច់ហ្នឹងលោកអ៊ីខៀវ សំផន គាត់មានដែលមកសួរសុខទុក្ខកងទ័ពដែរ?

ដែនៈ គាមនេះ ។

វណ្ណៈ៖ បាទ ។

ដែន ៖ គាត់ធ្លាប់មកតែកន្លែងសាគាំងកន្លែងសម្តេចអីហ្នឹង ។

វណ្ណៈ៖ បាទ ។

ដែនៈ បើយើងជាកងទ័ពយើងមិនដែលបាននៅយើងនៅតែសមរភូមិឯណោះ ដូចនេះយើងមិនដែលបានឃើញទេ ។

វណ្ណៈ៖ ចឹងខ្ញុំសួរតែមួយសំនួរពីរទៀតទេ?

ដែនៈ បាទ ។

វណ្ណៈ៖ ដូចជាភូមិវាលហាត់ ចឹងហេតុអីបានជាគេដាក់ភូមិវាលហាត់ចឹងពូ?

ដែន ៖ ដូចខ្ញុំប្រាប់ចឹងនៅកន្លែងហ្នឹង មានវាលសម្រាប់ហាត់ទាហាន ហាត់កងទ័ពណាស់ ។

វណ្ណៈ ចឹងមានហាត់ទាហាន?

ដែនៈ បាទ ។

វណ្ណៈ៖ ចឹងបានជាប់ឈ្មោះភូមិវាលហាត់ដល់សព្វថ្ងៃចឹងទៅ?

ដែន ៖ បាទ ។

វណ្ណៈ៖ ចឹងខ្ញុំដូចជាមិនមានអីចង់សួរពូទៀតទេ ចឹងពូអីចង់និយាយបន្ថែមទៀតទេ?

ដែន ៖ ខ្ញុំអត់មានអីចង់និយាយទៀត ។

វណ្ណៈ៖ ចឹងខ្ញុំអរគុណពូច្រើនហើយ ។

ដែន ៖ បាទ ។

**«ចប់»**